# សេចក្តីប្រកាសពត៌មាន

## ស្តីពីលទ្ធផលនៃការប្រជុំផ្សព្វផ្សាយលើការព្រមព្រៀង នៃការប៉ាន់ស្មានអត្រាផ្ទុកមេរោគអេដស៍នៅប្រទេសកម្ពុជាសំរាប់ឆ្នាំ ២០០៦

នៅថ្ងៃទី ២៨ មិថុនា ឆ្នាំ ២០០៧ មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ នៃក្រសួងសុខាភិបាលកម្ពុជា បានប្រកាសនូវការប៉ាន់ប្រមាណជាផ្លូវការ អំពីអត្រាប្រេវ៉ាឡង់មេរោគអេដស៍ ទូទាំងប្រទេស លើមនុស្សពេញវ័យគឺមាន 0.៩% នៅក្នុងឆ្នាំ ២០០៦ ។ តួលេខនេះមានន័យថា នៅក្នុងចំណោមប្រជាពលរដ្ឋកម្ពុជា ១០០ នាក់ អាយុ ១៥-៤៩ ឆ្នាំ មានមនុស្ស ១នាក់ មានផ្ទុកមេរោគអេដស៍ ហើយតំណាងនូវការធ្លាក់ចុះនៃអត្រាប្រេវ៉ាឡង់ ប្រហែលជិតពាក់កណ្តាល ប្រៀបធៀបទៅនឹងការប៉ាន់ប្រមាណ ១.២% នៅឆ្នាំ ២០០៣ ។

អត្រាប៉ាន់ប្រមាណជាផ្លូវការនេះ គឺជាលទ្ធផលនៃកិច្ចប្រជុំព្រមព្រៀងរវាងមន្ត្រីបច្ចេកទេស នៃមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ ហើយ និងក្រុមអ្នកជំនាញការ-ទីប្រឹក្សា បច្ចេកទេសអន្តរជាតិនានា ដែលបានជួបប្រជុំគ្នាធ្វើការងារនេះ ពីថ្ងៃទី ២៥-២៩ មិថុនា ឆ្នាំ ២០០៧ ។

ការប៉ាន់ប្រមាណនេះ ពឹងផ្អែកលើប្រភពទិន្នន័យផ្សេងៗ រួមមាន ទិន្នន័យបានមកពីការអង្កេតអត្រាផ្ទុកមេរោគអេដស៍ ឆ្នាំ ២០០៦ ការអង្កេតប្រជាសាស្ត្រ និងសុខភាពឆ្នាំ ២០០៥ និងទិន្នន័យស្ថិតិប្រជាពលរដ្ឋ ដែលបានមកពីវិទ្យាស្ថានជាតិស្ថិតិ ។ ក្រុមអ្នកជំនាញការបានកត់សំគាល់ថា ការប្រើប្រាស់ទិន្នន័យ ដែលបានមកពីប្រភពផ្សេងៗ អាចជួយធ្វើអោយប្រសើរឡើងនូវការប៉ាន់ប្រមាណ អត្រាផ្ទុកមេរោគអេដស៍ នាពេលនេះ ។

ការប៉ាន់ប្រមាណជាផ្លូវការ នូវអត្រាផ្ទុកមេរោគអេដស៍ 0.៩% គឺខ្ពស់ជាង ការប៉ាន់ប្រមាណដែលរកឃើញនៅក្នុងការអង្កេតប្រជាសាស្ត្រ និងសុខភាព ឆ្នាំ ២០០៥ ។ មូលហេតុនៃភាពខុសគ្នានេះ គឺថា ការអង្កេតប្រជាសាស្ត្រ និងសុខភាពឆ្នាំ ២០០៥ ជាការអង្កេតធ្វើឡើងនៅតាមផ្ទះ របស់ប្រជាពលរដ្ឋ ដែលទំនងជាមិនបានបញ្ចូលក្រុមប្រជាពលរដ្ឋផ្សេងៗទៀត ដែលមានការប្រឈមមុខនឹងការឆ្លងមេរោគអេដស៍ខ្ពស់ ។

ទោះបីជាអត្រាប្រេវ៉ាឡង់មេរោគអេដស៍ នៅក្នុងប្រទេសកម្ពុជា មានការធ្លាក់ចុះជាបន្តបន្ទាប់ក៏ដោយ ក៏មនុស្សពេញវ័យ អាយុ ១៥-៤៩ ឆ្នាំ នៅក្នុងប្រទេសកម្ពុជាប្រហែល ៦៥000 នាក់ កំពុងមានផ្ទុកមេរោគអេដស៍ ហើយអត្រាឆ្លងមេរោគអេដស៍ថ្មី និងចំនួនអ្នកស្លាប់ដោយជំងឺអេដស៍កំពុងតែកើតមានជាបន្ត ។

ក្រុមអ្នកជំនាញការបានកត់សំគាល់ថា ការធ្លាក់ចុះនៃអត្រាប្រេវ៉ាឡង់ គឺថា លទ្ធផលរយៈពេលវែងនៃការធ្លាក់ចុះរបស់ការឆ្លងមេរោគអេដស៍ថ្មី ដែលប៉ាន់ប្រមាណថា បានចាប់ផ្តើមនាឆ្នាំ ១៩៩៨-១៩៩៩ ។ កម្មវិធីបង្ការនានាដែលអនុវត្តដោយរាជរដ្ឋាភិបាលកម្ពុជា ធានាថា អត្រាឆ្លងនៃមេរោគអេដស៍ត្រូវបានកាត់បន្ថយជាអតិបរិមា ។

កម្មវិធីប្រយុទ្ធនឹងជំងឺអេដស៍ ត្រូវតែធានាអោយមាននិរន្តភាព ដើម្បីកាត់បន្ថយនូវការឆ្លងជា អតិបរិមាក្នុងចំណោមប្រជាពលរដ្ឋកម្ពុជា ។ រាជរដ្ឋាភិបាលកម្ពុជាប្តេជ្ញាបន្តកិច្ចខិតខំប្រឹងប្រែងប្រយុទ្ធនឹងការរាតត្បាត នៃមេរោគអេដស៍ ហើយធានាថា ការទទួលបាននូវការបង្ការ និងការថែទាំព្យាបាល ក្លាយជាការពិតសំរាប់អ្នកដែលត្រូវការ ។ ការបន្តគាំទ្រពីដៃគូជាតិ និងអន្តរជាតិ គឺមានសារៈសំខាន់ណាស់ ក្នុងការបន្តជំរុញការឆ្លើយតបទៅនឹងមេរោគអេដស៍-ជំងឺអេដស៍ ដើម្បីបង្ការនូវការលេចឡើងជាថ្មី នៃការរាតត្បាត នៃមេរោគអេដស៍នាពេលអនាគត ។